**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៥០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់បញ្ចូលមន្ទីរពេទ្យជ័យវរ្ម័នទី៧ ជាគ្រឹះស្ថានក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានដាក់បញ្ចូលមន្ទីរពេទ្យជ័យវរ្ម័នទី៧ ដែលមានទីតាំងស្ថិតនៅវិថីសាលដីហ្គោល ភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ជាគ្រឹះស្ថានក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល មានឋានៈស្មើនាយកដ្ឋាន។

**មាត្រា២.-**

មន្ទីរពេទ្យជ័យវរ្ម័នទី៧ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- រ៉ាប់រងផ្តល់សេវាសុខាភិបាលផ្នែកជំងឺកុមារទូទៅ ពិគ្រោះនិងព្យាបាល ជំងឺវះកាត់ទូទៅ ជំងឺវះកាត់បេះដូង និងជំងឺវះកាត់ប្រព័ន្ធប្រសាទកណ្តាល ដែលបានបញ្ជូនមកឬដែលបានសុំមកពិនិត្យសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ
- ផ្តល់ឲ្យអ្នកជំងឺកុមារនូវការព្យាបាលរោគនិងផ្តល់សេវាពិនិត្យតាមដានផ្ទៃពោះ ប្រសូតិកម្មក្នុងផ្នែកសម្ភព តាមស្តង់ដាបច្ចេកទេស
- ធ្វើប្រតិបត្តិការក្នុងផ្នែកបង្ការការពារជំងឺនិងអប់រំសុខភាពកុមារនិងស្ត្រីមានផ្ទៃពោះ ផ្តល់ការថែទាំព្យាបាលជំងឺស្រាលឬជំងឺធ្ងន់ទៅតាមឯកទេស
- ផ្តល់ជូនអ្នកជំងឺគ្រប់រូបនូវរាល់ការពិនិត្យព្យាបាលតាមតម្រូវការនិងលទ្ធភាពរបស់សាមីអង្គភាព
- ពិគ្រោះយោបល់និងព្យាបាលអ្នកជំងឺទូទៅ ដោយមិនមានការរើសអើង និងប្រកបដោយគុណភាព ត្រឹមត្រូវតាមកម្រិតស្តង់ដាបច្ចេកទេសដោយសមធម៌
- ចាត់ចែងឲ្យបានល្អត្រឹមត្រូវនូវការព្យាបាលសង្គ្រោះបន្ទាន់ លើគ្រប់ផ្នែកនិងអាស្រ័យតាមមធ្យោបាយរបស់មន្ទីរពេទ្យ
- ធ្វើប្រតិបត្តិការដោយខ្លួនឯងខាងផ្នែកផ្តល់ឈាម
- ចូលរួមបណ្តុះបណ្តាលនិងស្រាវជ្រាវវិស័យវេជ្ជសាស្ត្រ និងសល្យសាស្ត្ររោគកុមារ និងប្រសូតិកម្មផ្នែកសម្ភព ព្រមទាំងជួយបណ្តុះបណ្តាលបុគ្គលិកនិងនិស្សិត
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងសុខាភិបាលប្រគល់ជូន។

**មាត្រា៣.-**

មន្ទីរពេទ្យជ័យវរ្ម័នទី៧ដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមន្ទីរពេទ្យជ័យវរ្ម័នទី៧ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ